**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៩៦/០០៦/២០០៥
ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៥
**សេចក្តីសម្រេច**
លេខ : ០៧០/០០២/២០០៥ កបធ.ច
ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ៥៣៨ រស ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តយល់ព្រម កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានអនុម័តយល់ព្រមតាមទម្រង់ និងគតិច្បាប់នេះ នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ផងដែរ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលសំណើនេះ នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៥

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា រដ្ឋសភា បានអនុវត្តយ៉ាងត្រឹមត្រូវ តាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នេះ ត្រូវបានប្រកាសឱ្យប្រើ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវ នូវបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា ទម្រង់នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

-យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលមាន ១៣ ជំពូក ៣៧ មាត្រា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**